**វេទិកាអ៊ីនធឺណិតភ្នំពេញ (PPIF) ឆ្នាំ ២០២៥**

**ប្រធានបទ៖ "រួមគ្នាលើកកម្ពស់អនាគតឌីជីថលនៅកម្ពុជា ប្រកបដោយបរិយាបន្ន"**

**កាលបរិច្ឆេទ៖** ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥

**ទីកន្លែង៖** សណ្ឋាគារ ហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ *(Google Maps)*

## ១. បរិបទឌីជីថលនៅកម្ពុជា

ដោយការវិវត្តន៍នៃបច្ចេកវិទ្យាឌីជីថលក្នុងសកលលោកមានការរីកចម្រើនខ្លាំង ដែលតម្រូវឱ្យប្រទេសកម្ពុជា ត្រូវធ្វើការអភិវឌ្ឍវិស័យឌីជីថលរបស់ខ្លួនផងដែរ។ ដើម្បីដើរឱ្យទាន់ការវិវត្តន៍ទាំងនោះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចឌីជីថល និងសង្គមឆ្នាំ២០២២ ដល់ ២០៣៥ ដែលមាន ចក្ខុវិស័យក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីជំរុញកំណើនសេដ្ឋកិច្ច រួមទាំងអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព និងការផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលទាំងនោះ ។ ក្របខ័ណ្ឌនេះត្រូវបានបង្កើតឡើងដោយមាន សសរស្តម្ភយុទ្ធសាស្ត្រចំនួនបី៖ (១). ពលរដ្ឋឌីជីថល ដែលផ្តោតលើការពង្រឹងសមត្ថភាពដល់ប្រជាពលរដ្ឋឱ្យមានជំនាញឌីជីថល និងការចូលប្រើប្រាស់។ (២). រដ្ឋាភិបាលឌីជីថល សំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈតាមរយៈឧបករណ៍ និងបច្ចេកវិទ្យាឌីជីថល និង (៣). អាជីវកម្មឌីជីថល ដែលលើកកម្ពស់ការច្នៃប្រឌិត និងការប្រកួតប្រជែងក្នុងវិស័យឯកជន។ បើទោះជាមានចក្ខុវិស័យប្រកបដោយមហិច្ឆិតាបែបនេះក៏ដោយ ក៏ប្រទេសកម្ពុជាប្រឈមមុខនឹងបញ្ហាជាច្រើនផងដែរ។

យោងតាមក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានឱ្យដឹងថា ប្រជាជនកម្ពុជាប្រហែល ៣០ភាគរយ(%) ប៉ុណ្ណោះដែលមានចំណេះដឹងផ្នែកឌីជីថលជាមូលដ្ឋាន ជាមួយនឹងគម្លាតយ៉ាងខ្លាំងក្នុងចំណោមប្រជាពលរដ្ឋនៅតាមជនបទ ជាពិសេសស្ត្រី និងសហគមន៍ក្រីក្រ។ បើគ្មានជំនាញឌីជីថលជាមូលដ្ឋានទេ ប្រជាពលរដ្ឋជាច្រើនមិនអាចចូលរួមយ៉ាងពេញលេញនៅក្នុងសេដ្ឋកិច្ចឌីជីថល ឬការពារខ្លួនពីការគំរាមកំហែងតាមអ៊ីនធឺណិតបានទេ ខណៈពេលដែលការជ្រៀតចូលអ៊ីនធឺណិតកំពុងកើនឡើង។ ចំពោះតម្លៃក្នុងការប្រើប្រាស់អ៊ីនធឺណិតល្បឿនលឿននៅមិនទាន់សមរម្យនោះទេ ដែលជាកត្តារារាំងដល់ការចូលរួមប្រើប្រាស់របស់ប្រជាពលរដ្ឋប្រកបដោយសមធម៌។ ដើម្បីកាត់បន្ថយហានិភ័យពីការជ្រៀតចូលតាមប្រព័ន្ធអ៊ីនធឺណិត និងហានិភ័យចំពោះទិន្នន័យបុគ្គលរបស់ប្រជាពលរដ្ឋ។ រដ្ឋាភិបាលកម្ពុជា កំពុងធ្វើសេចក្តីព្រាងច្បាប់ឌីជីថល សំខាន់ៗមួយចំនួនរួមមាន ច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ច្បាប់ស្តីពីសន្តិសុខសាយប័រ ច្បាប់កិច្ចការពារទិន្នន័យបុគ្គល និងច្បាប់ស្តីពីរដ្ឋាភិបាលឌីជីថល ដែលមានបំណងលើកកម្ពស់សុវត្ថិភាព និងទំនុកចិត្តលើប្រព័ន្ធឌីជីថល។ ទោះជាយ៉ាងណាក៏ដោយ អង្គការសង្គមស៊ីវិលដែលធ្វើការងារលើវិស័យសិទ្ធិឌីជីថល និងអ្នកសង្កេតការណ៍អន្តរជាតិ បានលើកឡើងពីការព្រួយបារម្ភចំពោះ លទ្ធភាពខ្ពស់របស់អាជ្ញាធរក្នុងការគ្រប់គ្រង ជាពិសេសទាក់ទងទៅនឹងសេរីភាពនៃការបញ្ចេញមតិ ភាពឯកជន និងការទទួលបានព័ត៌មាន ដែលអាចប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ដែលមានចែងក្នុងសេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិ។ ស្របពេលដែលបច្ចេកវិទ្យាដែលកំពុងរីកចម្រើនខ្លាំង ការប្រើប្រាស់បញ្ញាសិប្បនិមិត្ត(AI) ក្នុងវិស័យសុខាភិបាល កសិកម្ម ការអប់រំ និងវិស័យផ្សេងៗទៀត វាក៏ផ្តល់នូវហានិភ័យផងដែរ ដោយសារតែក្រមសិលធម៌ក្នុងការប្រើប្រាស់បច្ចេកវិទ្យានៅមានកម្រិតទាបនៅឡើយ ដោយហានិភ័យទាំងនោះរួម

មាន ការបៀតបៀនតាមអ៊ីនធឺណិត ជាពិសេសលើអ្នកសារព័ត៌មាន សកម្មជនជាស្ត្រី ការចែកចាយព័ត៌មានមិនពិត និងព័ត៌មានក្លែងក្លាយដែលបង្កើតដោយបញ្ញាសិប្បនិម្មិត(AI) និងការបោកប្រាស់តាមអ៊ីនធឺណិត លើប្រជាពលរដ្ឋដែលមានអនក្ខរកម្មឌីជីថល។ បញ្ហាទាំងនេះកាន់តែធ្ងន់ធ្ងរឡើងដោយសារកង្វះការអប់រំឌីជីថល ដល់ប្រជាពលរដ្ឋ និងចំណាត់ការផ្លូវច្បាប់ចំពោះជនល្មើសនៅមានកម្រិត។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ តម្រូវឱ្យមានការសហការពីភាគីពាក់ព័ន្ធរួមមានរាជរដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍អន្តរជាតិ។

ដូច្នេះហើយវេទិកាអ៊ីនធឺណិតភ្នំពេញ ដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលកិច្ចសន្ទនាដោយបើកចំហរការចែករំលែកបទពិសោធន៍ និងការអនុវត្តល្អៗ និងជម្រុញឱ្យមានការបង្កើតគោលនយោបាយឌីជីថល ដែលផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន។

## ២. តើវេទិកាអ៊ីនធឺណិតភ្នំពេញ (PPIF) ជាអ្វី?

វេទិកាអ៊ិនធឺណិតភ្នំពេញ គឺជាវេទិកាពហុភាគីប្រចាំឆ្នាំ ដែលផ្តួចផ្តើមដោយក្រុមការងារសិទ្ធិឌីជីថល(DRWG) ដើម្បីលើកកម្ពស់សិទ្ធិឌីជីថល និងសេរីភាពអ៊ីនធឺណិតនៅកម្ពុជា។ ដោយមានការចូលរួមពី អង្គការសង្គមស៊ីវិល រដ្ឋាភិបាល វិស័យឯកជន អ្នកជំនាញ និងដៃគូជាតិ និងអន្តរជាតិ ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍ ពិភាក្សាអំពីបញ្ហាប្រឈម និងឱកាសក្នុងការជជែកពិភាក្សា អំពីគោលនយោបាយដែលពាក់ព័ន្ធនឹងសិទ្ធិឌីជីថល។

## ៣. គោលបំណងរួមនៃវេទិកាអ៊ិនធឺណិតភ្នំពេញ (PPIF)

វេទិកាអ៊ិនធឺណិតភ្នំពេញ មានគោលបំណងលើកកម្ពស់ និងការពារសិទ្ធិឌីជីថល និងសេរីភាព អ៊ីនធឺណិតនៅកម្ពុជាតាមរយៈកិច្ចសន្ទនា ការជជែកដេញដោល និងការចែករំលែកបទពិសោធន៍ និងចំនុចដែលរៀនសូត្របានមេរៀន ពីការអនុវត្ត តាមរយៈវិធីសាស្រ្តពហុភាគី។

## ៤. គោលបំណង៖

១, លើកកម្ពស់ការយល់ដឹងអំពីក្រមខណ្ឌច្បាប់ដែលពាក់ព័ន្ធបញ្ញាសិប្បនិម្មិត និងបទល្មើសបច្ចេកវិទ្យាព័ត៌មាន។

២, បង្កើតជាវេទិកាចែករំលែកចំណេះដឹងអំពីសិទ្ធិឌីជីថល សេរីភាពអ៊ីនធឺណិត ព័ត៌មានមិនពិត និងបញ្ញាសិប្បនិម្មិត

៣, ផ្តល់ឱកាសដល់អ្នកចូលរួម ក្នុងការសន្ទនាដោយផ្ទាល់ជាមួយ ភាគីពាក់ព័ន្ធដើម្បីឱ្យមានកំណែទម្រង់លើគោលនយោបាយ និងបទបញ្ញត្តិ ដែលពាក់ព័ន្ធនឹងសិទ្ធិឌីជីថល។

## ៥. លទ្ធផលរំពឹងទុក៖

១, អ្នកចូលរួមនឹងបានស្វែងយល់កាន់ច្បាស់អំពីវឌ្ឍនភាព និងខ្លឹមសារសំខាន់ៗនៃក្រមខណ្ឌច្បាប់ដែលពាក់ព័ន្ធនឹងសិទ្ធិឌីជីថល។

២, អ្នកចូលរួមទទួលបានចំណេះដឹងថ្មីអំពីការប្រើប្រាស់សិទ្ធិឌីជីថល និងសេរីភាពអ៊ីនធឺណិតប្រកបដោយប្រសិទ្ធិភាព និងសុវត្ថិភាព។

៣, អ្នកចូលរួមនឹងបានជជែកពិភាក្សាដោយផ្ទាល់ជាមួយភាគីពាក់ព័ន្ធលើគោលនយោបាយ និងបទបញ្ញត្តិដែលពាក់ព័ន្ធនឹងសិទ្ធិឌីជីថល។

## ៦. របៀបវារៈ

| ពេលវេលា | របៀបវារៈ | វាគ្មិន/អ្នកសម្របសម្រួល |
|---|---|---|
| ០៨:០០ - ០៨:៣០ | ការអញ្ជើញមកដល់ និងចុះឈ្មោះរបស់ភ្ញៀវកិត្តិយស | ក្រុមការងារ សិទ្ធិឌីជីថល |
| | **គោរពទង់ជាតិកម្ពុជា និងប្រកាសហេតុ** | |
| ០៨:៣០ – ០៨:៤០ | សុន្ទរកថាស្វាគមន៍ដោយ **លោកស្រី ស៊ិន ពុទ្ធារី**<br>នាយិកាអង្គការ គ.ស.ក | ពិធីការនី លោកស្រី<br>**ណុប លីនដា** |
| ០៨:៤០ - ០៨:៥០ | សុន្ទរកថាបើកកម្មវិធី ដោយ **ឯកឧត្តម ជា វ៉ាន់ដេត**<br>រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | |
| ០៨:៥០- ១០:០០ | បទបង្ហាញស្តីពី "**ក្រមខណ្ឌច្បាប់ដែលពាក់ព័ន្ធនឹងបញ្ញាសិប្បនិម្មិត (AI)**"<br>**សំនួរ-ចម្លើយ** | **តំណាងពី** ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| ១០:០០ - ១០:២០ | សម្រាកអាហារសម្រន់ និងថតរូបអនុស្សាវរីយ៍ | |
| ១០:២០ - ១២:០០ | **កិច្ចពិភាក្សាជុំ៖** "ការប្រើប្រាស់ និងការគ្រប់គ្រងបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត(AI) ដើម្បីជំរុញការអភិវឌ្ឍប្រទេសកម្ពុជា"<br>• **តំណាងពី ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍** (MPTC)<br>• **សមាគមសហគ្រិនវ័យក្មេងកម្ពុជា** (YEAC)<br>• **អង្គការទិន្នន័យអំពីការអភិវឌ្ឍ** (ODC)<br>• **លោក ង៉ែត ម៉ូសេ** | អ្នកសម្រប់សម្រួល៖<br>**១, អង្គការមណ្ឌលព័ត៌មាន ស្ត្រីកម្ពុជា** (WMC)<br>**២, លោក** Chanroeun |
| ១២:០០ - ០១:៣០ | សម្រាកអាហារថ្ងៃត្រង់ | |
| ០១:៣០ - ០២:០០ | ធ្វើបទបង្ហាញស្តីពី "**ការផ្សព្វផ្សាយពិទស្សនវិស័យមុខរបប និងការងារសម្រាប់ជុវជនក្នុងបរិបទឌីជីថល**" | **តំណាងពី** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ០២:០០ - ០៣:០០ | <u>សិក្ខាសាលាតាមប្រធានបទ៖ ជុំទី១</u><br>**<u>បន្ទប់ទី១:</u>** (ផ្សាយផ្ទាល់)<br>❖ ប្រធានបទ៖ "**ការណែនាំអំពី បញ្ញាសិប្បនិម្មិត (AI) និងរបៀបប្រើប្រាស់ប្រកបដោយការទទួលខុសត្រូវ និងសុវត្ថិភាព។**" | |

<table>
<tr><td></td><td>• វាគ្មិន៖ បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (CADT)<br>• អ្នកទទួលខុសត្រូវ៖ UNESCO Cambodia<br><br><u>បន្ទប់ទី២:</u><br>❖ ប្រធានបទ៖ (បញ្ជាក់ជូនពេលក្រោយ)<br>• វាគ្មិន៖ (បញ្ជាក់ជូនពេលក្រោយ)<br>• អ្នកទទួលខុសត្រូវ៖ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)<br><br><u>បន្ទប់ទី៣:</u><br>❖ ប្រធានបទ៖ "យុវជនចែករំលែកបទពិសោធន៍លើហានិភ័យទាក់ទងនឹងករណីឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត និងសេរីភាពអ៊ីនធឺណិត"<br>• វាគ្មិន៖ (បញ្ជាក់ជូនពេលក្រោយ)<br>• អ្នកទទួលខុសត្រូវ៖ អង្គការថែរក្សាភាសាជនជាតិដើមភាគតិច (CIPL)</td><td></td></tr>
<tr><td>០៣:០០ - ០៣:១៥</td><td>សម្រាកអាហារសម្រន់</td><td></td></tr>
<tr><td>០៣:១៥ - ០៤:១៥</td><td><u>សិក្ខាសាលាតាមប្រធានបទ៖ ជុំទី២</u><br><u>បន្ទប់ទី១:</u><br>❖ ប្រធានបទ៖ "អំពើហឹង្សាទាក់ទងយេនឌ័រដែលសម្របសម្រួលដោយបច្ចេកវិទ្យា"<br>• វាគ្មិន៖ (បញ្ជាក់ជូនពេលក្រោយ)<br>• អ្នកទទួលខុសត្រូវ៖ អង្គការទិន្នន័យអំពីការអភិវឌ្ឍ (ODC)<br><br><u>បន្ទប់ទី២:</u></td><td></td></tr>
</table>

| | | |
|---|---|---|
| | ❖ ប្រធានបទ៖ "**ជម្រុញការតភ្ជាប់បណ្ដាញអ៊ីនធឺណិតដល់តំបន់ដាច់ស្រយាល**"<br>• វាគ្មិន៖ (បញ្ជាក់ជូនពេលក្រោយ)<br>• អ្នកទទួលខុសត្រូវ៖ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)<br><br>**<u>បន្ទប់ទី៣:</u>**<br>❖ ប្រធានបទ៖ "**ការពិនិត្យការពិត** (Fact checking)"<br>• វាគ្មិន៖ (បញ្ជាក់ជូនពេលក្រោយ)<br>• អ្នកទទួលខុសត្រូវ៖ ខេមបូចា (CamboJA) | |
| ០៤:១៥ - ០៤:៥០ | ការបង្ហាញលទ្ធផលពិភាក្សានៃបន្ទប់នីមួយៗ | **អ្នកសម្របសម្រួលតាមបន្ទប់នីមួយៗ** |
| ០៤:៥០ - ០៥:០០ | បិទកម្មវិធីដោយ **លោកស្រី សខតា ច័ន្ទត្រីស្នា** នាយិកាអង្គការមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC) | ក្រុមការងារ សិទ្ធិឌីជីថល |

កំណត់សម្គាល់៖ យើងខ្ញុំសូមរក្សាសិទ្ធិក្នុងការកែប្រែកម្មវិធីក្នុងករណីចាំបាច់។ សូមអរគុណ!